## សហព័ន្ធខ្មែរកម្ពុជាក្រោម
KHMERS KAPUCHEA-KROM FEDERATION

KHMERKROM.ORG



សន្និសីទសិទ្ធិមនុស្ស | ថ្ងៃសៅរ៍ ទី ៨ ខែធ្នូ ឆ្នាំ ២០១៨

# ខួប ៧០ ឆ្នាំ
នៃ
# សេចក្ដីប្រកាសជាសកលរបស់ អ.ស.ប. ស្ដីពីសិទ្ធិមនុស្ស
ការអបអរ, ការក្រោកឈរ និង ការទាមទារសិទ្ធិជាមូលដ្ឋាន

សម្រាប់
# ជនជាតិដើមនៅវៀតណាម និង កម្ពុជាក្រោម

រៀបចំដោយ សហព័ន្ធខ្មែរកម្ពុជាក្រោម



Multicultural Center Hall

647 SOUTH KING ROAD SAN JOSE, CA 95116 U.S.A.

ការចុះឈ្មោះ | សូមផ្ញើឈ្មោះរបស់លោកអ្នកទៅអ៊ីមែល INFO@KHMERKROM.ORG

សហព័ន្ធខ្មែរកម្ពុជាក្រោម
KHMERS KAMPUCHEA-KROM FEDERATION
www.khmerkrom.org / info@khmerkrom.org

…………………………

សេចក្តីប្រកាសព័ត៌មាន

# សន្និសីទសិទ្ធិមនុស្ស
## ខួប ៧០ ឆ្នាំ នៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស
## ការអបអរសាទរ, ការក្រោកឈរ និង ការទាមទារសិទ្ធិមូលដ្ឋាន
## សម្រាប់ជនជាតិដើមនៅក្នុងប្រទេសវៀតណាម និង កម្ពុជាក្រោម

សហព័ន្ធខ្មែរកម្ពុជាក្រោម (KKF) នឹងរៀបចំសន្និសីទសិទ្ធិមនុស្សមួយ ក្រោមប្រធានបទ "**ខួប ៧០ ឆ្នាំ នៃសេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស, ការអបអរសាទរ, ការក្រោកឈរ និងការទាមទារសិទ្ធីជាមូលដ្ឋានសម្រាប់ជនជាតិដើមនៅក្នុងប្រទេសវៀតណាម និង កម្ពុជាក្រោម**" ។ សន្និសីទនេះ នឹងធ្វើនៅទីក្រុង San Jose រដ្ឋ California សហរដ្ឋ អាមេរិក នៅថ្ងៃសៅរ៍ ទី ៨ ខែធ្នូ ឆ្នាំ ២០១៨ ចាប់ពីម៉ោង ៩ ព្រឹកដល់ម៉ោង ៤ រសៀល ដើម្បីអបអរសាទរ ខួប ៧០ ឆ្នាំ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (UNHR) និង បន្តលើកកម្ពស់ការយល់ដឹងអំពីការរំលោភសិទ្ធិមនុស្ស នាពេលបច្ចុប្បន្ន របស់រដ្ឋាភិបាលវៀតណាម ប្រឆាំងនឹងខ្មែរក្រោមដែលជាជនជាតិដើម នៃដែនដីកម្ពុជាក្រោម និងជនជាតិដើម នានានៅក្នុងប្រទេសវៀតណាម ។

ជារៀងរាល់ឆ្នាំ នៅថ្ងៃទី ១០ ខែធ្នូ ប្រជាពលរដ្ឋនៅជុំវិញពិភពលោក ប្រារព្ធទិវាសិទ្ធិមនុស្ស ជាថ្ងៃដែលមហាសន្និបាតរបស់អង្គការសហប្រជាជាតិ បានអនុម័តសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សនៅឆ្នាំ ១៩៤៨ ។ ជាអកុសល ជនជាតិដើមខ្មែរនៅកម្ពុជាក្រោម និងជនជាតិដើមនានានៅក្នុងប្រទេសវៀតណាម នៅមិនទាន់បានទទួលនូវសិទ្ធិជាមូលដ្ឋានដែល

បានចែងនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សនៅឡើយ ជាពិសេសសិទ្ធិដើម្បីអបអរសាទរទិវាសិទ្ធិមនុស្សដោយសេរី ។

ក្នុងឋានៈជារដ្ឋសមាជិកនៃអង្គការសហប្រជាជាតិ វៀតណាមបានចុះហត្ថលេខាលើសន្ធិសញ្ញាចំនួន ៧ ក្នុងចំណោម ៩ នៃសន្ធិសញ្ញាជាមួយអង្គការសហប្រជាជាតិ និងបានចុះហត្ថលេខាអនុម័តសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើម ។ រដ្ឋាភិបាលវៀតណាមបានបដិសេធមិនទទួលស្គាល់ជនជាតិដើមនៅវៀតណាម និង បានកំណត់នូវអត្តសញ្ញាណរបស់ពួកគេថាជា ជនជាតិភាគតិច ។ ដោយខ្វះការទទួលស្គាល់នេះហើយ ជនជាតិដើមនៅក្នុងប្រទេសវៀតណាម រាប់បញ្ចូលទាំងខ្មែរក្រោមនៅដែនដីកម្ពុជាក្រោម ផងបានប្រឈមមុខនឹងការរំលោភបំពានសិទ្ធិមនុស្ស និងការធ្វើឧបនេយ្យកម្មឱ្យទៅជាយួន ដែលជាបញ្ហាគួរឱ្យព្រួយបារម្ភយ៉ាងខ្លាំង ។

អ្នកតស៊ូមតិដើម្បីសិទ្ធិមនុស្ស, មន្ត្រីរដ្ឋាភិបាល, អ្នកសិក្សា, សមាជិកនៃសង្គមស៊ីវិល និងតំណាងជនជាតិដើមនៅក្នុងប្រទេសវៀតណាម រួមមាន **ជនជាតិតៃ ហ្មុង** និង **ម៉ុងតៃញ៉ា** នឹងត្រូវបានអញ្ជើញឱ្យថ្លែងសុន្ទរកថានៅក្នុងសន្និសីទនេះ ដើម្បី "**លើកកម្ពស់, ការចូលរួម និង ឆ្លុះបញ្ចាំង**" លើសេចក្តីប្រកាសជាសកលរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្ស និង ផ្តោតលើកិច្ចពិភាក្សាពីរបៀបប្រើប្រព័ន្ធសិទ្ធិមនុស្សអន្តរជាតិ ដើម្បីការពារ និង លើកកម្ពស់សិទ្ធិជាមូលដ្ឋានរបស់ជនជាតិដើមនៅក្នុងប្រទេសវៀតណាម និង កម្ពុជាក្រោម ។

**របៀបវារៈ នៃ សន្និសីទ៖**

***ផ្នែកទី ១៖ ការលើកកម្ពស់សិទ្ធិមនុស្សដែលបានចែងនៅក្នុងសេចក្តីប្រកាសជាសកលរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្ស (UDHR) ដើម្បីលើកកម្ពស់ និង ការពារសិទ្ធិជាមូលដ្ឋានរបស់ជនជាតិដើមនៅប្រទេសវៀតណាម និង កម្ពុជាក្រោម ។***

**វាគ្មិន៖**

- **បណ្ឌិត** Joshua Cooper ជានាយកប្រតិបត្តិ នៃវិទ្យាស្ថានសិទ្ធិមនុស្សហាវ៉ៃ

**ក្រុមតំណាងជនជាតិដើមនៅវៀតណាមរួមមាន៖**

- **លោក តោ គិម ថុង** ជាទីប្រឹក្សាជាន់ខ្ពស់ និង អតីតអធិបតី នៃសហព័ន្ធខ្មែរកម្ពុជាក្រោម

- **អ្នកស្រី** Siang Bacthi ជានាយកប្រតិបត្តិ នៃ មជ្ឈមណ្ឌលសិក្សាជនជាតិតៃ
- **លោក** James Her ជាអធិបតី និង សមាជិកសភាពិភពលោក នៃជនជាតិហ្មុង
- **លោក** Kok Ksor ជាប្រធាន នៃមូលនិធិម៉ុងតែញ៉ា

***ផ្នែកទី ២៖ សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯងនៅក្នុងច្បាប់អន្តរជាតិ***

- **លោក** Paul Strauss ជាសមាជិកព្រឹទ្ធសភាសហរដ្ឋអាមេរិក មកពី DC នៃសហរដ្ឋអាមេរិក
- **អ្នកស្រី** Julie Duval ជាមន្ត្រីកម្មវិធី នៃ អង្គការប្រជាជាតិ និង ប្រជាជនគ្មានតំណាង (UNPO)

***ផ្នែកទី ៣៖ សិទ្ធិសេរីភាព និង ជំនឿសាសនា***

- អ្នកស្រី Tina L. Mufford ជាមន្ត្រីជាន់ខ្ពស់ផ្នែកវិភាគនយោបាយរបស់គណៈកម្មការសហរដ្ឋអាមេរិកទទួលផ្នែកសេរីភាពសាសនាអន្តរជាតិ
- ព្រះតេជព្រះគុណ TT Dhammo ជាប្រធានគណៈកម្មការសាសនាអន្តរជាតិ នៃសហព័ន្ធខ្មែរកម្ពុជាក្រោម

***ផ្នែកទី ៤៖*** *សិទ្ធិក្នុងការទទួលបានព័ត៌មាន និងសេរីភាពក្នុងការបញ្ចេញមតិ*

- លោក Phil Robertson នាយករងប្រចាំអាស៊ី នៃ អង្គការឃ្លាំមើលសិទ្ធិមនុស្ស Human Rights Watch

***ផ្នែកទី ៥៖*** *ការអនុវត្តនូវរបៀបវារៈឆ្នាំ ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ចំនួន ១៧ ចំណុច ដើម្បីរួមចំណែកដល់ការអនុវត្តនូវសិទ្ធិមនុស្សឱ្យបានពេញលេញ*

- លោក Sereivuth Prak ជាប្រធានប្រតិបត្តិ នៃសហព័ន្ធខ្មែរកម្ពុជាក្រោម
- បណ្ឌិត Joshua Cooper ជានាយកប្រតិបត្តិ នៃវិជ្ជាស្ថានសិទ្ធិមនុស្សរដ្ឋហាវ៉ៃ